ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ......៤៧......ភសរ

# សេចក្ដីសំរេច
## ស្ដីពី
## ការកំណត់ក្រមសីលធម៌សំរាប់
## មន្ត្រីអនុវត្តគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី

៣៕៤

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦ /នស/៩៤/០៩ ចុះថ្ងៃ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃ២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃ២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានកំណត់ក្រមសីលធម៌សំរាប់មន្ត្រីអនុវត្តគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីដូចខាងក្រោម ៖

១. មន្ត្រីអនុវត្តគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីទាំងអស់ជាអ្នកអនុវត្តការងារសំខាន់ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលក្នុងការកែទំរង់ដីធ្លី ត្រូវប្ដេជ្ញាចិត្តខ្ពស់ ប្រកបដោយមនសិការវិជ្ជាជីវៈ សេចក្ដីថ្លៃថ្នូរ មានភាពស្មោះត្រង់ តម្លាភាព និងមានអភិបាលកិច្ចល្អក្នុងគ្រប់ការងារ ដោយត្រូវប្រកាន់ខ្ជាប់ជាប្រចាំនូវក្រមសីលធម៌នេះ សំដៀរូមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីសំរេចឱ្យបាននូវការីកចំរើនប្រកបដោយចីរភាព និងយុត្តិធម៌ ។

២. មន្ត្រីអនុវត្តគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ត្រូវទទួលខុសត្រូវចំពោះការផ្តល់សេវាសាធារណៈ ដោយត្រូវធ្វើឱ្យមានការជឿជាក់ពីសំណាក់សាធារណជន និងលើការបំរើសេវាសាធារណៈ ។ មន្ត្រីទាំងអស់ត្រូវអនុវត្តការងារតាមច្បាប់ អនុក្រឹត្យ បទដ្ឋានគតិយុត្ត និងបទបញ្ជាពាក់ព័ន្ធនានាដោយកំណត់ច្បាស់លាស់ថា ការបំរើប្រយោជន៍សាធារណៈជាភារកិច្ចចំបង ។

មន្ត្រីទាំងអស់ត្រូវមានភក្តីភាពចំពោះគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដោយប្រកាន់ជាប់នូវសុចរិតភាព ភាពមិនលំអៀងដែលមានទិសដៅណែនាំច្បាស់លាស់ និងមានតម្លាភាពលើគ្រប់ទិដ្ឋភាពការងារ ។

៣. មន្ត្រីទាំងអស់ត្រូវបំរើសេវាកម្មជូនសាធារណជនដោយមិនទារសគុណ កំរៃជើងសាក្រៅពីតំលៃសេវាជាផ្លូវការដែលរដ្ឋបានកំណត់ និងមិនត្រូវស្វែងរកប្រយោជន៍ផ្ទាល់ខ្លួនក្នុងពេលអនុវត្តការងារ ទោះបីតាមរូបភាពណាក៏ដោយ ។ មិនត្រូវប្រព្រឹត្តអំពើណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់គំរោង និងកិត្យានុភាពរបស់ក្រសួងឡើយ ។

៤. ត្រូវគោរពសិទ្ធិ សេរីភាព សេចក្តីថ្លៃថ្នូរ និងសមភាពរបស់ប្រជាពលរដ្ឋជាអតិថិជន ដោយ ៖

- មិនត្រូវមានភាពលំអៀង មិនត្រូវបំភាន់ព័ត៌មានដែលនាំឱ្យមានការសំរេចខុស មិនត្រូវនាំសហការីក្រោមឱវាទរបស់ខ្លួន ឬសាធារណជន ឱ្យធ្វើខុសដោយបំពានច្បាប់ ឬបំភាន់ ក្លែងឯកសារឡើយ
- ត្រូវគោរពសេរីភាពក្នុងជំនឿនិងសាសនា និងគ្មានការរើសអើង
- មិនត្រូវឃុបឃិតលើអំពើខុសឆ្គងរបស់បុគ្គលណាម្នាក់ឡើយ ទោះបីជាអ្នកនោះបំរើការ ឬ តំណាងឱ្យគំរោងក៏ដោយ
- ត្រូវមានសមានចិត្តទូលំទូលាយក្នុងការប្រាស្រ័យទាក់ទងជាមួយសាធារណជន
- ត្រូវមានអាកប្បកិរិយាប្រកបដោយការគោរព មានយុត្តិធម៌ សមធម៌ ព្រមទាំងការពារសិទ្ធិរបស់អ្នកនៅក្រោមឱវាទរបស់ខ្លួន រួមទាំងការគោរព និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ឬការបង្កើតសមាគម
- ត្រូវចាត់វិធានការម៉ឺងម៉ាត់ និងជាបន្ទាន់ក្នុងការកែលំអ នៅពេលដែលរកឃើញកំហុសឆ្គងរបស់មន្ត្រីក្រោមឱវាទ និងរាយការណ៍ជូនថ្នាក់លើដើម្បីមានវិធានការតាមច្បាប់
- ត្រូវលើកទឹកចិត្តមន្ត្រីក្រោមឱវាទដែលបានផ្តល់ព័ត៌មានអំពីការប្រព្រឹត្តអំពើខុសឆ្គងរបស់មន្ត្រីក្នុងការអនុវត្តការងារគំរោង
- មន្ត្រីអនុវត្តគំរោងទាំងអស់ត្រូវពាក់ឯកសណ្ឋាន ផ្លាកសញ្ញាសំគាល់ខ្លួនដែលមានឈ្មោះ មុខតំណែង និងអង្គភាពគ្រប់ពេលចុះបំពេញភារកិច្ច និងរាល់ពេលប្រាស្រ័យទាក់ទងជាមួយសាធារណជន។ ត្រូវបិទបញ្ជីឈ្មោះមន្ត្រីអនុវត្តគំរោងនៅមុខការិយាល័យធ្វើការ ដែលអាចឱ្យសាធារណជនមើលឃើញបាន និងត្រូវធ្វើបច្ចុប្បន្នភាពរាល់ពេលដែលមានការផ្លាស់ប្តូរ ។

៥. ត្រូវគោរពឋានានុក្រមក្នុងការអនុវត្តការងារគំរោង ៖

- ប្រសិនបើមានបញ្ជាឱ្យធ្វើការងារអ្វីមួយ ហើយអ្នកអនុវត្តផ្ទាល់ពិនិត្យដោយជឿជាក់ថាមិនត្រឹមត្រូវ អាចខុសច្បាប់ អសីលធម៌ រំលោភនឹងក្រមសីលធម៌ និងមិនស្របតាមគោលការណ៍អភិបាលកិច្ចល្អ ត្រូវរាយការណ៍

ជាបន្ទាន់ទៅថ្នាក់លើតាមគ្រប់រូបភាពដែលអាចធ្វើបាន ឬត្រូវរាយការណ៍ជូនថ្នាក់លើបន្ទាប់ ដើម្បីសុំគោលការណ៍ដឹកនាំ

- ក្នុងករណីមានទំនាស់ពីផលប្រយោជន៍ក្នុងការចុះបញ្ជីដីធ្លី ត្រូវរាយការណ៍សុំគោលការណ៍ដឹកនាំពីថ្នាក់លើ ដោយបង្ហាញពីលទ្ធភាពនៃការដោះស្រាយដោយសន្តិវិធី ដែលភាគីទំនាស់ទាំងសងខាងអាចទទួលយកបាន
- មិនត្រូវប្រកាន់គ្រួសារនិយម បក្សពួកនិយម ដោយជ្រើសរើសអ្នកសាច់ញាតិ បក្សពួកដែលអសមត្ថភាពឱ្យមកទទួលតំណែងក្នុងយន្តការណាមួយរបស់គំរោងឡើយ
- មិនត្រូវប្រើប្រាស់មុខតំណែង សិទ្ធិទទួលខុសត្រូវក្នុងការងារណាមួយ ឬព័ត៌មានបច្ចេកទេសរបស់គំរោង ទៅប្រើប្រាស់សំរាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍ផ្សេងទៀតឡើយ
- មិនត្រូវចូលរួមជាមួយអំពើកេងបន្លំ ពុករលួយ ស៊ីសំណូក ឬសកម្មភាពមិនប្រក្រតីលើផ្នែកហិរញ្ញវត្ថុផ្សេងទៀត ។

៦. ត្រូវប្រើប្រាស់មូលនិធិរបស់គំរោងឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អតាមគោលការណ៍កំណត់ ៖

- សម្ភារៈ បរិក្ខារ មធ្យោបាយ និងធនធានហិរញ្ញវត្ថុរបស់គំរោង ត្រូវបានប្រើប្រាស់សំរាប់តែគោលដៅអនុវត្តគំរោងប៉ុណ្ណោះ
- មិនត្រូវរែអង្គាស ឬទទួលថវិកាក្រៅផ្លូវការ អំណោយ ប្រាក់សគុណដែលកើតចេញអំពីការងាររបស់ខ្លួន និងមិនត្រូវគំរាមកំហែង ឬបង្អាប់សាធារណជនឱ្យបង់សេវាក្រៅផ្លូវការឡើយ
- មិនត្រូវកាត់ប្រាក់ឧបត្ថម្ភប្រចាំខែរបស់មន្ត្រីអនុវត្តគំរោងដែលត្រូវទទួលបានឡើយ ហើយមន្ត្រីអនុវត្តគំរោង មិនត្រូវសូកប៉ាន់ ថ្នាក់លើរបស់ខ្លួនដើម្បីគោលបំណងណាមួយឡើយ ។

៧. មន្ត្រីអនុវត្តគំរោងត្រូវប្រកាន់ខ្ជាប់នូវសេចក្តីថ្លៃថ្នូរនៅពេលអនុវត្តការងារ ដោយត្រូវផ្តល់ព័ត៌មានពេញលេញ អំពីដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធគ្រប់ដំណាក់កាល និងតំរូវការឯកសារចាំបាច់ដែលត្រូវមាន ដូចជាតម្លៃសេវាផ្លូវការដែលម្ចាស់ដីត្រូវបង់ ហើយត្រូវឆ្លើយសំណួរទាំងឡាយឱ្យបានទាន់ពេលវេលា ពិតប្រាកដ និងពេញលេញ ។ មិនត្រូវរារាំង ឬបន្ទុចបង្អាក់សាធារណជនដែលមានសិទ្ធិតាមផ្លូវច្បាប់ទទួលបានពត៌មានឡើយ

៨. ក្នុងរយៈពេលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ប្រសិនបើមានបណ្តឹងតវ៉ា មន្ត្រីចុះបញ្ជីដីធ្លីត្រូវមានសុចរិតភាពក្នុងការបកស្រាយពន្យល់ ឬ ដំណោះស្រាយផ្សេងៗតាមផ្លូវច្បាប់ និងតាមលក្ខណៈបច្ចេកទេស ។ ក្នុងករណីមានការឃុបឃិត បង្ខំទារសគុណ ប្រជាពលរដ្ឋម្ចាស់ដីមានសិទ្ធិប្តឹងតវ៉ា ដោយបញ្ជាក់ពីឈ្មោះ មុខតំណែងរបស់មន្ត្រីនោះ។ រាល់បណ្តឹងតវ៉ាត្រូវបានចុះក្នុងបញ្ជី និងធ្វើការស៊ើបអង្កេតដោយហ្មត់ចត់តាមប្រព័ន្ធទទួល និងដោះស្រាយបណ្តឹង ។

**ប្រការ ២.-**

ក្រមសីលធម៌នេះអនុវត្តចំពោះតែមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលកំពុងអនុវត្តគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ទាំងនៅថ្នាក់កណ្តាល និងនៅថ្នាក់ខេត្ត-ក្រុង ។

**ប្រការ ៣.-**

មន្ត្រីអនុវត្តគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ទាំងនៅថ្នាក់កណ្តាល និងថ្នាក់ខេត្ត-ក្រុង ដែលអនុវត្តផ្ទុយពីខ្លឹមសារក្នុងប្រការ ១ នៃសេចក្តីសំរេចនេះ នឹងឈានដល់ការអនុវត្តតាមមាត្រាទាំងឡាយ ដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ នាយកគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី នាយកប្រតិបត្តិគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីខេត្ត-ក្រុង និងមន្ត្រីអនុវត្តគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីទាំងអស់ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ២០០៦

**ទេសរដ្ឋមន្ត្រី**

អ៊ឹម ឈុនលឹម

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់សាលាខេត្តក្រុង អនុវត្តគំរោង រៀបចំដែនដី និងរដ្ឋបាលដីធ្លី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ